# 01 한글 익히기 I

ការរៀនហាន់ហ្គឹល(អក្សរកូរ៉េ)១

## 1 한글 소개 ការណែនាំពី ហាន់ហ្គឹល(អក្សរកូរ៉េ)

K-1

ហាន់ហ្គឹល ត្រូវបានស្តេចសេចុងនៃសម័យចូសន់ បង្កើតឡើងនៅក្នុងឆ្នាំ១៤៤៣។ មុននោះខណៈពេលដែលតួអក្សរមានតិចពេក គេបានយកហាន់ចា(អក្សរចិន)របស់ចិនមកប្រើប្រាស់។ ក៏ប៉ុន្តែ ហាន់ចា គឺមានផលលំបាកខ្លាំងសម្រាប់បុគ្គលដែលមិនបានទទួលការអប់រំ។ ហេតុដូច្នេះហើយ ទើបបានជាស្តេចសេចុងបានបង្កើតហាន់ហ្គឹលឡើងមក ដើម្បីឲ្យរាស្ត្រធម្មតាអាចប្រើប្រាស់បានដោយភាពងាយស្រួល។

### (1) តួអក្សរដែលមានស្រៈតិច គឺត្រូវបានបង្កើតឡើងតាមវិធីនេះ។



| | |
|---|---|
| • | មេឃ |
| ㅡ | ដី |
| ㅣ | មនុស្ស |

| | |
|---|---|
| ㅣ+ • = | ㅏ [a] |
| ㅣ + • • = | ㅑ [ja] |
| • + ㅡ = | ㅗ [o] |
| • • + ㅡ = | ㅛ [jo] |

តួអក្សររបស់ស្រៈមូលដ្ឋាននៅក្នុងភាសាកូរ៉េត្រូវបានបង្កើតឡើងដោយយកគម្រូទៅតាមការមើលឃើញពីរូបរាងនៃមេឃ(•), ដី(ㅡ) និងមនុស្ស(ㅣ)។ ហើយផ្អែកតាមតួអក្សររបស់ស្រៈមូលដ្ឋានទាំង៣នេះ បានបង្កើតចេញទៅជាស្រៈដែលមានដូចជា៖ ‘ㅏ, ㅑ, ㅓ, ㅕ, ㅗ, ㅛ, ㅜ, ㅠ’។ ចំណែកឯស្រៈដែលនៅសល់ក៏បានបង្កើតចេញពីការផ្សំផ្គុំតួអក្សរមូលដ្ឋាននេះដែរ។

### (2) តួអក្សរដែលមានព្យញ្ជនៈតិច គឺត្រូវបានបង្កើតឡើងតាមវិធីនេះ។




តួអក្សរកូរ៉េ ‘ㄱ, ㄴ, ㅁ, ㅅ, ㅇ’ ត្រូវបានបង្កើតដោយផ្អែកទៅតាមរូបរាងនៃសរីរាង្គដែលប្រើប្រាស់នៅពេលធ្វើការបញ្ចេញសម្លេង។

| | | | | |
|---|---|---|---|---|
| ㄱ | [k/g] | → ㅋ | [kʰ] | ដើម្បីអាចបញ្ចេញនូវសូរខ្យល់ខ្លាំងចេញមកបាន គេបានបន្ថែមឆ្នូតមួយឆ្នូតថែមពីលើតួអក្សរដើម ហើយបង្កើតបានជាㅋ, ㅌ, ㅍ, ㅊ។ |
| ㄷ | [t/d] | → ㅌ | [tʰ] | |
| ㅂ | [p/b] | → ㅍ | [pʰ] | |
| ㅈ | [ʧ/ʤ] | → ㅊ | [ʧʰ] | |

| | | |
|---|---|---|
| ㄱ [k/g] | → ㄲ [k´] | ដើម្បីអាចបញ្ចេញនូវសូរតានតឹង គេបានបន្ថែមតួអក្សរដដែលមួយទៀតពីលើតួអក្សរដើម បង្កើតបានទៅជាㄲ, ㄸ, ㅃ, ㅆ, ㅉ។ |
| ㄷ [t/d] | → ㄸ [t´] | |
| ㅂ [p/b] | → ㅃ [p´] | |
| ㅅ [s] | → ㅆ [s´] | |
| ㅈ [ʧ/ʤ] | → ㅉ [ʧ´] | |

**(3)** ចំពោះព្យាង្គ គឺអាចសរសេរឡើងបានតាមវិធីនេះ។

នៅពេលដែលយើងធ្វើការផ្សំ ស្រៈនិងព្យញ្ជនៈ គឺយើងបង្កើតបានជា ព្យាង្គ។ សម្រាប់ ព្យាង្គ ភាសាកូរ៉េ គឺចាំបាច់ត្រូវតែមានស្រៈនិងព្យញ្ជនៈ។ ប្រសិនបើនៅខាងមុខស្រៈ មិនមានព្យញ្ជនៈនោះទេ គឺគេតែងតែប្រើ ‘ㅇ’។ ចំពោះព្យញ្ជនៈ‘ㅇ’ នៅពេលដែលវាប្រើនៅខាងមុខស្រៈ គឺមិនត្រូវបានគេអាននោះទេ។ គេអានតែ‘ㅇ’ដែលនៅបន្ទាប់ពីស្រៈតែប៉ុណ្ណោះ។ ក្នុងព្យាង្គមួយ គឺមិនអាចមានស្រៈនិងព្យញ្ជនៈនៅដាច់ដោយឡែកគ្នានោះទេ។ សម្រាប់ព្យញ្ជនៈ គឺអាចនៅខាងមុខឬនៅពីក្រោយនៃព្យាង្គបាន។

| | | | |
|---|---|---|---|
| ① | ព្យញ្ជនៈ + ស្រៈ (បញ្ឈរ) | CV | 나 |
| | ព្យញ្ជនៈ<br>+<br>ស្រៈ (ផ្ដេក) | C<br>V | 노 |
| ② | (‘ㅇ’គឺមិនអាននោះទេ) ព្យញ្ជនៈ + ស្រៈ(បញ្ឈរ) | CV | 아 |
| | (‘ㅇ’គឺមិនអាននោះទេ) ព្យញ្ជនៈ<br>+<br>ស្រៈ(ផ្ដេក) | C<br>V | 오 |
| ③ | ព្យញ្ជនៈ + ស្រៈ(បញ្ឈរ)<br>+<br>ព្យញ្ជនៈ(ជើង) | CV<br>C | 밥 |
| | ព្យញ្ជនៈ<br>+<br>ស្រៈ(ផ្ដេក)<br>+<br>ព្យញ្ជនៈ(ជើង) | C<br>V<br>C | 문 |
| ④ | (‘ㅇ’គឺមិនអាននោះទេ) ព្យញ្ជនៈ<br>+<br>ស្រៈ(បញ្ឈរ) + ព្យញ្ជនៈ(ជើង) | CV<br>C | 안 |
| | (‘ㅇ’គឺមិនអាននោះទេ) ព្យញ្ជនៈ<br>+<br>ស្រៈ(ផ្ដេក)<br>+<br>ព្យញ្ជនៈ(ជើង) | C<br>V<br>C | 웅 |

## 2 모음 1 ស្រៈ ១

K-2

ស្រៈក្នុងភាសាកូរ៉េ គឺមាន ២១តួ។ ចំពោះស្រៈ គឺមានស្រៈបញ្ឈរ(ㅣ, ㅏ, ㅑ, ㅓ, ㅕ) និងស្រៈផ្ដេក(ㅡ, ㅗ, ㅛ, ㅜ, ㅠ)។

**1.** សម្លេងរបស់ស្រៈ



តោះ! ចាប់ពីពេលនេះ យើងទៅរៀនអំពីសម្លេងរបស់ស្រៈទាំងអស់គ្នា។ ជាដំបូងសូមត្រៀមកញ្ចក់។
សូមស្ដាប់ស្រៈ ហើយសាកល្បងឆ្លុះកញ្ចក់បណ្ដើរ ធ្វើតាមរូបបបូរមាត់របស់រូបភាពបណ្ដើរ។
យើងនឹងអនុវត្ត ដោយធ្វើការបែងចែកជាស្រៈបញ្ឈរនិងស្រៈផ្ដេក។

| ស្រៈបញ្ឈរ | | ស្រៈផ្ដេក | |
|---|---|---|---|
| ㅣ [i] |  | ㅡ [ɨ] |  |
| ㅏ [a] |  | ㅗ [o] |  |
| ㅑ [ja] |  [i] + [a] | ㅛ [jo] |  [i] + [o] |
| ㅓ [ʌ] |  | ㅜ [u] |  |
| ㅕ [jʌ] |  [i] + [ʌ] | ㅠ [ju] |  [i] + [u] |



តោះ! យើងសាកល្បងអនុវត្តម្តងទៀត។

**(1)** សូមសាកល្បងធ្វើការបញ្ចេញសម្លេង ‘ㅏ’។ សូមសាកល្បងធ្វើការបញ្ចេញសម្លេង ‘ㅓ’។ តើរូបរាងបបូរមាត់រវាង ‘ㅏ’ និង ‘ㅓ’ ខុសគ្នាយ៉ាងដូចម្តេចទៅ?
សូមហាមាត់ឲ្យធំហើយបញ្ចេញសម្លេង‘ㅏ’ បន្ទាប់មកសូមបិទមាត់បន្តិចហើយសាកល្បងបញ្ចេញសម្លេង‘ㅓ’។ សូមយកចិត្តទុកដាក់ទៅលើរូបរាងមាត់របស់អ្នកបណ្តើរ សាកល្បងបញ្ចេញសម្លេង‘ㅏ’ និង ‘ㅓ’ ដដែលៗឲ្យបានច្រើនដងបណ្តើរ។

| | | | |
|---|---|---|---|
| ㅏ<br>[a] |  | ㅓ<br>[ʌ] |  |

**(2)** សូមធ្វើការបញ្ចេញសម្លេង ‘ㅜ’។ សូមធ្វើការបញ្ចេញសម្លេង ‘ㅗ’ តើរូបរាងបបូរមាត់រវាង ‘ㅜ’ និង ‘ㅗ’ ខុសគ្នាយ៉ាងដូចម្តេចទៅ?
នៅពេលដែលយើងបញ្ចេញសម្លេង ‘ㅜ’ បបូរមាត់របស់យើងនឹងប្រែជារង្វង់ និងបូញទៅខាងមុខ តែនៅពេលបញ្ចេញសម្លេង ‘ㅗ’ យើងធ្វើមាត់បូញជារង្វង់ទៅមុខដូចគ្នា តែយើងត្រូវហាមាត់ធំបន្តិច។ សូមយកចិត្តទុកដាក់ទៅលើរូបរាងមាត់របស់អ្នកបណ្តើរ សាកល្បងបញ្ចេញសម្លេង ‘ㅜ’ និង ‘ㅗ’ ឆ្លាស់គ្នាដដែលៗឲ្យបានច្រើនដង។

| | | | |
|---|---|---|---|
| ㅜ<br>[u] |  | ㅗ<br>[o] |  |

**(3)** សូមសាកល្បងធ្វើការបញ្ចេញសម្លេង ‘ㅣ’ ។ សូមសាកល្បងធ្វើការបញ្ចេញសម្លេង ‘ㅡ’។ តើរូបរាងបបូរមាត់រវាង ‘ㅣ’ និង ‘ㅡ’ខុសគ្នាយ៉ាងដូចម្តេចទៅ?
នៅពេលដែលយើងបញ្ចេញសម្លេង ‘ㅣ’ អណ្តាតរបស់យើងនឹងរំកិលទៅមុខជាងពេលបញ្ចេញសម្លេង ‘ㅡ’។ ចំពោះ ‘ㅡ’ មិនត្រូវការអណ្តាតលានទៅខាងមុខ ហើយក៏មិនចាំបាច់បូញមាត់ជារង្វង់ក៏បាន ហើយក៏មិនចាំបាច់ហាមាត់ធំពេកក៏បាន។ សូមសាកល្បងបញ្ចេញសម្លេង ដោយបង្ហើបមាត់តែបន្តិច ដូចពេលយើងគ្រាន់តែហាមាត់ល្មមធម្មតាៗចេញខ្យល់តាមមាត់បាន។ សូមយកចិត្តទុកដាក់ទៅលើរូបរាងមាត់របស់អ្នកបណ្តើរ សាកល្បងបញ្ចេញសម្លេង‘ㅣ’ និង ‘ㅡ’ដដែលៗឲ្យបានច្រើនដងបណ្តើរ។

| | | | |
|---|---|---|---|
| ㅣ<br>[i] |  | ㅡ<br>[ɨ] |  |



តោះ! ចាប់ពីពេលនេះ យើងសាកទៅអនុវត្តស្រៈផ្សំ ដែលកើតចេញពីការបញ្ចូលនូវស្រៈទាំងពីរប្រភេទនោះទាំងអស់គ្នា។ ស្រៈផ្សំ គឺជាស្រៈដែលមានឆ្នូតផ្ដេកខ្លីពីរឆ្នូត នៅក្នុងចំណោមស្រៈបញ្ឈរដែលមានដូចជា‘ㅑ, ㅕ’ និងនៅក្នុងចំណោមស្រៈផ្ដេក ជាស្រៈដែលមានឆ្នូតបញ្ឈរពីរ គឺមាន ‘ㅛ, ㅠ’ ។

**(1)** សូមសាកល្បងធ្វើការបញ្ចេញសម្លេង‘ㅑ’។ សូមសាកល្បងធ្វើការបញ្ចេញសម្លេង‘ㅕ’។ នៅពេលបញ្ចេញសម្លង‘ㅑ’ សូមបញ្ចេញសម្លេង‘ㅣ’ឲ្យខ្លី ហើយបញ្ចេញសម្លេង ‘ㅏ’ឲ្យបានវែង។ នៅពេលបញ្ចេញសម្លេង ‘ㅕ’ សូមធ្វើការបញ្ចេញសម្លេង‘ㅣ’ឲ្យបានខ្លី ហើយបញ្ចេញសម្លេង ‘ㅓ’ឲ្យបានវែង។ នៅពេលបញ្ចេញសម្លេង ស្រៈទាំងពីរនេះ ត្រូវបញ្ចេញសម្លេងក្នុងប្រវែងដូចគ្នា មិនអាចបញ្ចេញសម្លេងដូចជាស្រៈផ្ដាច់ខ្លួននៃស្រៈពីរបាននោះឡើយ។

| | | | |
|---|---|---|---|
| ㅑ<br>[ja] | <br>[i] + [a] | ㅕ<br>[jʌ] | <br>[i] + [ʌ] |

**(2)** សូមសាកល្បងធ្វើការបញ្ចេញសម្លេង ‘ㅛ’។ សូមសាកល្បងធ្វើការបញ្ចេញសម្លេង ‘ㅠ’។ នៅពេលបញ្ចេញសម្លង ‘ㅛ’សូមបញ្ចេញសម្លេង ‘ㅣ’ឲ្យខ្លី ហើយបញ្ចេញសម្លេង ‘ㅗ’ឲ្យបានវែង។ នៅពេលបញ្ចេញសម្លេង ‘ㅠ’ សូមធ្វើការបញ្ចេញសម្លេង‘ㅣ’ឲ្យបានខ្លី ហើយបញ្ចេញសម្លេង ‘ㅜ’ឲ្យបានវែង។ នៅពេលបញ្ចេញសម្លេង ស្រៈទាំងពីរនេះ ត្រូវបញ្ចេញសម្លេងក្នុងប្រវែងដូចគ្នា មិនអាចបញ្ចេញសម្លេងដូចជាស្រៈផ្ដាច់ខ្លួននៃស្រៈពីរបាននោះឡើយ។

| | | | |
|---|---|---|---|
| ㅛ<br>[jo] | <br>[i] + [o] | ㅠ<br>[ju] | <br>[i] + [u] |

## 2. ការសរសេរស្រៈ

បើដូច្នេះ តើស្រៈ សរសេរយ៉ាងដូចម្ដេចទៅ? ចំពោះស្រៈឆ្នូតបញ្ឈរនៅពេលសរសេរគឺសរសេរពីលើចុះមកក្រោម ចំណែកឯស្រៈផ្ដេក ពេលសរសេរគឺត្រូវសរសេរដេញពីឆ្វេងទៅស្ដាំ។

| ស្រៈបញ្ឈរ | | | ស្រៈផ្ដេក | | |
|---|---|---|---|---|---|
| ㅣ<br>[i] | <br>(○) | <br>(X) | ㅡ<br>[ɨ] | <br>(○) | <br>(X) |



អញ្ជឹងយើងទៅសាកសរសេរជាមួយគ្នា! ចំពោះស្រៈបញ្ឈរដែលមានស្តង់ដារមនុស្សដែលកំពុងឈរ គឺយើងសរសេរ ឆ្នូតបញ្ឈររាងវែង ហើយឆ្នូតផ្តេករាងខ្លី។ ចំណែកឯស្រៈផ្តេកដែលមានស្តង់ដារដីដែលរាបស្មើ គឺយើងត្រូវធ្វើការសរសេរ ឆ្នូតផ្តេករាងវែង ហើយឆ្នូតបញ្ឈររាងខ្លី។ សូមស្តាប់សម្លេងស្រៈហើយថាតាមបណ្តើរ សរសេរតាមបណ្តើរ។

| ស្រៈ | លំដាប់នៃការសរសេរ | ការសរសេរ | | | | | |
|---|---|---|---|---|---|---|---|
| ㅣ [i] | ㅣ ① | | | | | | |
| ㅏ [a] | ㅏ ① ② | | | | | | |
| ㅑ [ja] | ㅑ ① ② ③ | | | | | | |
| ㅓ [ʌ] | ㅓ ① ② | | | | | | |
| ㅕ [jʌ] | ㅕ ① ② ③ | | | | | | |
| ㅡ [ɨ] | ㅡ ① | | | | | | |
| ㅗ [o] | ㅗ ① ② | | | | | | |
| ㅛ [jo] | ㅛ ① ② ③ | | | | | | |
| ㅜ [u] | ㅜ ① ② | | | | | | |
| ㅠ [ju] | ㅠ ① ② ③ | | | | | | |



តើសរសេររួចរាល់ហើយមែនទេ? លើកនេះ សូមស្តាប់ម្តងទៀត ហើយថាតាម។

ក្នុងតួអក្សរ ដាច់ខាតត្រូវតែមានស្រៈ និងព្យញ្ជនៈនៅជាមួយគ្នា។ ដូច្នេះហើយ ក្នុងករណីដែលគ្មានព្យញ្ជនៈ ដំបូង គឺគេសរសេរ ‘ㅇ’ដែលគ្មានសម្លេងជំនួសវិញ។ ចំពោះស្រៈបញ្ឈរគឺសរសេរ‘ㅇ’នៅខាងឆ្វេង ហើយចំពោះស្រៈផ្តេក គឺសរសេរ‘ㅇ’នៅពីខាងលើ។

| | | |
|---|---|---|
| ㅇ | ㅏ | [a] |

| | |
|---|---|
| ㅇ<br>ㅗ | [o] |



សូមស្តាប់ ហើយថាតាមបណ្តើរ សរសេរបណ្តើរ។

| ស្រៈ | ការបញ្ចេញសម្លេង | ការសរសេរ | | | | | |
|---|---|---|---|---|---|---|---|
| ㅣ | [i] | 이 | 이 | 이 | | | |
| ㅏ | [a] | 아 | 아 | 아 | | | |
| ㅑ | [ja] | 야 | 야 | 야 | | | |
| ㅓ | [ʌ] | 어 | 어 | 어 | | | |
| ㅕ | [jʌ] | 여 | 여 | 여 | | | |
| ㅡ | [ɨ] | 으 | 으 | 으 | | | |
| ㅗ | [o] | 오 | 오 | 오 | | | |
| ㅛ | [jo] | 요 | 요 | 요 | | | |
| ㅜ | [u] | 우 | 우 | 우 | | | |
| ㅠ | [ju] | 유 | 유 | 유 | | | |

## 연습 ការអនុវត្ត

1. សូមសាកល្បងធ្វើការបញ្ចេញសម្លេងស្រៈខាងក្រោមម្តងមួយៗ។ រួចរាល់ហើយមែនទេ? បើអញ្ចឹង សូមធ្វើការស្តាប់ CD ដើម្បីឆែកមើលថាអ្នកបានបញ្ចេញសម្លេងត្រូវដែរឬទេ។ សូមប្រុងប្រយ័ត្នចំពោះស្រៈដែលខុស ដោយសាកល្បងស្តាប់ម្តងទៀត ហើយថាតាម។

(1) 아 어 오 우 으　　(2) 오 아 어 우 이
(3) 야 여 요 유　　(4) 요 야 여 유

2. សូមស្តាប់ ហើយជ្រើសរើសចម្លើយដែលត្រឹមត្រូវ។

(1) 아 오　　(2) 우 으　　(3) 어 오
(4) 야 아　　(5) 오 요　　(6) 여 유

3. សូមស្តាប់ ហើយធ្វើការផ្គូរផ្គងតួអក្សរទៅតាមលំដាប់លំដោយ។ តើវានឹងចេញទៅជារូបភាពអ្វី?

이 •　　• 우

아 •　　• 여

으 •

정답 2. (1) 아 (2) 우 (3) 오 (4) 야 (5) 요 (6) 유 3. ☆

4. សូមស្តាប់ ហើយសរសេរអក្សរកូរ៉េដែលអ្នកបានលឺ។

| | | | | |
|---|---|---|---|---|
| (1) 2 | | | | |
| (2) 5 | | | | |
| (3)  | | | | |
| (4)  | | | | |
| (5)  | | | | |
| (6)  | | | | |



តើសរសេររួចរាល់ហើយមែនទេ? បន្ទាប់មកទៀត សូមអ្នកបញ្ចេញសម្លេងបណ្តើរ សរសេរឲ្យបាន៣ដង ទៀតបណ្តើរ។

정답 (1) 이 (2) 오 (3) 아이 (4) 오이 (5) 우유 (6) 여우

## 3 모음 2 ស្រៈ ២

K-3



តោះ! ពីពេលនេះទៅ យើងសាកល្បងរៀនពីស្រៈផ្សេងទៀតទាំងអស់គ្នា។
សូមស្តាប់ CD ហើយសាកល្បងថាតាម។

| | | | | | |
|---|---|---|---|---|---|
| ㅐ [ɛ] | ㅏ + ㅣ | ㅘ [wa] | ㅗ + ㅏ | ㅙ [wɛ] | ㅗ + ㅐ |
| ㅔ [e] | ㅓ + ㅣ | ㅝ [wʌ] | ㅜ + ㅓ | ㅞ [we] | ㅜ + ㅔ |
| ㅒ [ jɛ] | ㅑ + ㅣ | ㅟ [y/wi] | ㅜ + ㅣ | ㅢ [ɨi] | ㅡ + ㅣ |
| ㅖ [ je] | ㅕ + ㅣ | ㅚ [ø/we] | ㅗ + ㅣ | | |

ក្នុងចំណោមស្រៈបញ្ឈរគឺមានស្រៈមួយចំនួនដូចជាស្រៈ'ㅒ, ㅖ' ដែលជាស្រៈដែលមានឆ្នូតផ្ដេកខ្លី ២ឆ្នូត និងស្រៈ 'ㅘ, ㅝ' ដែលជាស្រៈផ្សំដែលមានស្រៈបញ្ឈរ និងស្រៈផ្ដេកនៅជាប់ជាមួយគ្នា។



តោះ! យើងសាកល្បងអនុវត្តម្ដងទៀត។

**(1)** សូមសាកល្បងបញ្ចេញសម្លេង 'ㅐ' និង 'ㅔ'។ ស្រៈទាំងពីរមានសម្លេងស្រដៀងគ្នាមែនទេ?
កាលពីមុន ការបញ្ចេញសម្លេងស្រៈទាំងពីរគឺខុសគ្នា ក៏ប៉ុន្តែសព្វថ្ងៃវាប្រែទៅជាស្រដៀងគ្នាវិញ។ ការបែងចែកការបញ្ចេញសម្លេងរបស់ស្រៈទាំងពីរគឺពិបាក។ ក៏ប៉ុន្តែកុំបារម្ភពេលដែលលឺថាមិនអាចធ្វើការបែងចែកវាបាន។ ព្រោះថាសូម្បីតែជនជាតិកូរ៉េមួយចំនួនធំក៏មិនសូវច្បាស់ដែរ។

| | |
|---|---|
| ㅐ [ɛ] | ㅔ [e] |

**(2)** សូមសាកល្បងបញ្ចេញសម្លេង 'ㅒ' និង 'ㅖ'។
ស្រៈទាំងពីរ សុទ្ធតែជាស្រៈផ្សំនាម ជាស្រៈបញ្ឈរ ដែលមានឆ្នូតផ្ដេក ២ឆ្នូត។ ហើយការបញ្ចេញសម្លេងរបស់ស្រៈទាំងពីរក៏ស្រដៀងគ្នាដែរ។ ការបែងចែកការបញ្ចេញសម្លេងរបស់ស្រៈទាំងពីរគឺពិបាក។ ក៏ប៉ុន្តែកុំបារម្ភពេលដែលលឺថាមិនអាចធ្វើការបែងចែកវាបាន។ ព្រោះថាវាដូចទៅនឹងស្រៈㅐ, ㅔ'អញ្ចឹងដែរ សូម្បីតែជនជាតិកូរ៉េមួយចំនួនធំក៏មិនសូវច្បាស់ដែរ។

| ㅒ | ㅖ |
|---|---|
| [jɛ] | [je] |

**(3)** សូមសាកល្បងបញ្ចេញសម្លេង 'ㅚ' និង 'ㅙ', 'ㅞ'។
ការបញ្ចេញសម្លេងរបស់ស្រៈទាំង៣ក៏ស្រដៀងគ្នាដែរ។ ស្រៈទាំង៣នេះ សុទ្ធតែជាស្រៈផ្សំដែលមានស្រៈផ្ដេកនិងស្រៈបញ្ឈរនៅជាមួយគ្នា។

| ㅚ | ㅙ | ㅞ |
|---|---|---|
| [we] | [wɛ] | [we] |

**(4)** សូមសាកល្បងបញ្ចេញសម្លេង 'ㅘ' និង 'ㅝ' ។
សូមសាកល្បងបញ្ចេញសម្លេងដដែលៗ។ ស្រៈទាំង២នេះ សុទ្ធតែជាស្រៈផ្សំដែលមានស្រៈផ្ដេកនិងស្រៈបញ្ឈរនៅជាមួយគ្នា។

| ㅘ | ㅝ |
|---|---|
| [wa] | [wʌ] |

**(5)** សូមសាកល្បងបញ្ចេញសម្លេង 'ㅟ' និង 'ㅚ' ឆ្លាស់គ្នាដដែលៗ។
ស្រៈទាំង២នេះ សុទ្ធតែជាស្រៈផ្សំដែលមានស្រៈផ្ដេកនិងស្រៈបញ្ឈរនៅជាមួយគ្នា។

| ㅟ | ㅚ |
|---|---|
| [y/wi] | [ø/we] |

**(6)** សូមសាកល្បងអាន 'ㅢ' ម្ដងទៀត។
សូមសាកល្បងអានសម្លេង 'ㅡ' រាងខ្លីបន្តិច បន្ទាប់មកប្រញាប់បញ្ចេញសម្លេងអាន 'ㅣ'។ ស្រៈទាំង២នេះ សុទ្ធតែជាស្រៈផ្សំដែលមានស្រៈផ្ដេកនិងស្រៈបញ្ឈរនៅជាមួយគ្នា។

| ㅢ |
|---|
| [ɨi] |



បើអញ្ចឹង តោះ! យើងទៅសាកសរសេរជាមួយគ្នា។ សូមស្ដាប់ CD ហើយសាកល្បង ថាតាមបណ្ដើរ សរសេរបណ្ដើរ។

| ស្រៈ | លំដាប់នៃការសរសេរ | ការសរសេរ | | | | | |
|---|---|---|---|---|---|---|---|
| ㅐ [ɛ] | ① ㅐ ③ ② | | | | | | |
| ㅔ [e] | ②③ ① ㅔ | | | | | | |
| ㅒ [jɛ] | ② ① ㅒ ④ ③ | | | | | | |
| ㅖ [je] | ③④ ① ② ㅖ | | | | | | |
| ㅘ [wa] | ③ ① ㅘ ④ ② | | | | | | |
| ㅝ [wʌ] | ④ ① ㅝ ②③ | | | | | | |
| ㅟ [y/wi] | ③ ① ㅟ ② | | | | | | |
| ㅚ [ø/we] | ① ③ ㅚ ② | | | | | | |
| ㅙ [wɛ] | ③⑤ ① ㅙ ④ ② | | | | | | |
| ㅞ [we] | ④⑤ ① ㅞ ②③ | | | | | | |
| ㅢ [ɨi] | ① ㅢ ② | | | | | | |



តើសរសេររួចរាល់ហើយមែនទេ? ម្ដងនេះ សូមស្ដាប់ស្រៈម្ដងទៀត ហើយថាតាម។

អ្នកមិនអាចសរសេរដូចនេះបានទេ។ សូមប្រុងប្រយ័ត្ន។

| | | | |
|---|---|---|---|
| ㅘ (○) | ㅝ (○) | ㅟ (○) | ㅞ (○) |
| ㅗㅓ (X) | ㅜㅏ (X) | ㅣㅜ (X) | ㅜㅔ (X) |

ក្នុងតួអក្សរ ដាច់ខាតត្រូវតែមានស្រៈនិងព្យញ្ជនៈនៅជាមួយគ្នា។ ដូច្នេះហើយ ក្នុងករណីដែលគ្មានព្យញ្ជនៈ ដំបូង គឺជាគេសរសេរ ‘ㅇ’ដែលគ្មានសម្លេងជំនួសវិញ។ ចំពោះស្រៈបញ្ឈរ គឺសរសេរ‘ㅇ’នៅខាងឆ្វេង ហើយចំពោះស្រៈផ្ដេក គឺសរសេរ‘ㅇ’នៅពីលើ។





សូមស្ដាប់ហើយថាតាមបណ្ដើរ សរសេរ 'ㅇ' ជាមួយនឹងស្រៈផ្សំបណ្ដើរ។

| ស្រៈ | ការបញ្ចេញសម្លេង | ការសរសេរ | | | | | |
|---|---|---|---|---|---|---|---|
| ㅐ | [ɛ] | 애 | 애 | 애 | | | |
| ㅔ | [e] | 에 | 에 | 에 | | | |
| ㅒ | [jɛ] | 얘 | 얘 | 얘 | | | |
| ㅖ | [je] | 예 | 예 | 예 | | | |
| ㅘ | [wa] | 와 | 와 | 와 | | | |
| ㅝ | [wʌ] | 워 | 워 | 워 | | | |
| ㅟ | [y/wi] | 위 | 위 | 위 | | | |
| ㅚ | [ø/we] | 외 | 외 | 외 | | | |
| ㅙ | [wɛ] | 왜 | 왜 | 왜 | | | |
| ㅞ | [we] | 웨 | 웨 | 웨 | | | |
| ㅢ | [ɨi] | 의 | 의 | 의 | | | |

## 연습 ការអនុវត្ត

1. សូមសាកល្បងបញ្ចេញសម្លេងស្រៈខាងក្រោមម្តងមួយៗ។ រួចរាល់ហើយមែនទេ? បើអញ្ចឹង សូមធ្វើការស្តាប់ CD ហើយធ្វើការគូសសញ្ញា 'O' ចំពោះចម្លើយដែលត្រូវនឹងការបញ្ចេញសម្លេង។ ចូរប្រុងប្រយ័ត្នចំពោះការបញ្ចេញសម្លេងដែលខុស ហើយសាកល្បងស្តាប់និងថាតាមម្តងទៀត ។

(1) 애 예 와 워　　(2) 위 의 와 웨
(3) 워 에 예 의　　(4) 왜 와 에 예

2. សូមស្តាប់ ហើយជ្រើសរើសចម្លើយដែលត្រឹមត្រូវ។

(1) 애 예　　(2) 웨 워
(3) 위 의　　(4) 와 왜

3. សូមស្តាប់ ហើយធ្វើការផ្គូរផ្គងតួអក្សរទៅតាមលំដាប់លំដោយ។ តើវាជានឹងចេញទៅជារូបភាពអ្វី?

아이　　　　　　얘
　　와　　　　위
여우　　에　　의
왜　　　오이　　우유

정답 1. (1) 와 (2) 위 (3) 워 (4) 예
2. (1) 애 (2) 웨 (3) 위 (4) 와
3. ☆ (위 → 여우 → 에 → 의 → 와 → 오이 → 위)

4. សូមស្តាប់ ហើយសរសេរអក្សរកូរ៉េដែលអ្នកបានលឺ។

| | | | | |
|---|---|---|---|---|
| (1)  | | | | |
| (2)  | | | | |
| (3)  | | | | |
| (4)  | | | | |
| (5)  | | | | |
| (6)  | | | | |



តើសរសេររួចរាល់ហើយមែនទេ? បន្ទាប់មកទៀត សូមអ្នកបញ្ចេញសម្លេងបណ្តើរ សរសេរឲ្យបាន៣ដង ទៀតបណ្តើរ។

정답 (1) 예 (2) 와 (3) 왜 (4) 와요 (5) 위에 (6) 외워요